ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីប្រកាសព័ត៌មាន

រាជធានីភ្នំពេញ៖ ថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០១៤ ដោយ អគ្គនាយកដ្ឋានពន្ធដារ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# កិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធប្រចាំខែសីហា ឆ្នាំ២០១៤

នាវេលាម៉ោង ០៨:៣០ នាទីព្រឹក ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៤ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំបូកសរុបការងារសារពើពន្ធប្រចាំខែសីហា ឆ្នាំ២០១៤ របស់អគ្គនាយកដ្ឋានពន្ធដារ អង្គប្រជុំដឹកនាំដោយឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ហើយមានការចូលរួមឯកឧត្តមអគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ លោកប្រធាន-អនុប្រធាននាយកដ្ឋាន លោកប្រធាន-អនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់ ក្រោមចំណុះអគ្គនាយកដ្ឋានពន្ធដារ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម **គង់ វិបុល** បានសំដែងអំណរសាទរដល់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការពន្ធដារគ្រប់ជាន់ថ្នាក់អំពីលទ្ធផលការងារប្រមូលចំណូលពន្ធដារ ដែលសម្រេចបានប្រចាំខែសីហា ឆ្នាំ២០១៤ និងជំរុញការលើកទឹកចិត្តថ្នាក់ដឹកនាំគ្រប់អង្គភាពពន្ធដារ សមាជិកអង្គប្រជុំដែលជាតំណាងមន្ត្រីពន្ធដារទូទាំងប្រទេសឲ្យខិតខំជំនះការលំបាក និងបញ្ហាប្រឈមនានា ខិតខំអនុវត្តភារកិច្ចប្រមូលចំណូលពន្ធគ្រប់ប្រភេទ ឲ្យបានសម្រេចតាមគោលដៅកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង បង្កើនការផ្តល់សេវាដល់អ្នកជាប់ពន្ធឲ្យបានល្អប្រសើរ ផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធទទួលសេវាងាយស្រួល ឆាប់រហ័សនៅគ្រប់ទីកន្លែងនិងអនុវត្តវិធានការនានាសំដៅធ្វើឲ្យបានសម្រេចគោលដៅចំណូលឆ្នាំ២០១៤។



 

ក្នុងខែសីហា ឆ្នាំ២០១៤នេះ អគ្គនាយកដ្ឋានពន្ធដារបានប្រមូលនិងបង់ប្រាក់ពន្ធចូលថវិកាជាតិបានចំនួន ៣៩៣.៧៧៥ លានរៀល (គិតជាដុល្លារ ៩៨,៤ លានដុល្លារ) ដែលចំណូលនេះមានការកើនឡើងលើសខែកក្កដាប្រមាណស្មើនឹង ៨,១% ។ ប្រសិនបើប្រៀបធៀបទៅនឹងចំណូលពន្ធប្រចាំខែសីហា ឆ្នាំ២០១៣ មានការកើនឡើងស្មើនឹង ៤២,២%។

ក្នុងរយៈពេលប្រាំបីខែនៃឆ្នាំ២០១៤ អគ្គនាយកដ្ឋានពន្ធដារប្រមូលចំណូលពន្ធដារ និងបង់ចូលថវិកាជាតិបានចំនួនស្មើនឹង ៧២,៦% នៃគោលដៅកំណត់ដោយច្បាប់ ក្នុងនោះថវិការជ្ជសម្រេចបានចំនួនស្មើនឹង ៧៤,៣% និងថវិការដ្ឋបាលថ្នាក់ក្រោមជាតិសម្រេចបានចំនួនស្មើនឹង ៦២,២%។ បើប្រៀបធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ២០១៣ ឃើញថា ការប្រមូលចំណូលពន្ធដារចូលថវិកាជាតិសម្រាប់ឆ្នាំ២០១៤នេះ មានការកើនឡើងចំនួនស្មើនឹង ១៩,០%។

ប្រសិនបើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នានៃឆ្នាំ២០១៣ ឃើញថា ចំណូលតាមប្រភេទពន្ធសំខាន់ៗមានការកើនឡើងស្ទើរតែទាំងអស់ ក្នុងនោះរួមមាន÷ ពន្ធលើប្រាក់បៀវត្សកើនឡើងចំនួនស្មើនឹង ៣៣,២% ពន្ធលើប្រាក់ចំណេញកើនឡើងចំនួនស្មើនឹង ២៩,៣% អាករលើតម្លៃបន្ថែមកើនឡើងចំនួនស្មើនឹង ១៣,៩% និងអាករពិសេសកើនឡើងចំនួនស្មើនឹង ១០,៨%។

បើប្រៀបធៀបទៅនឹងរយៈពេល ០៨ខែ ដូចគ្នានៃឆ្នាំ២០១៣ ឃើញថា ចំណូលពន្ធតាមសកម្មភាពអាជីវកម្មមានការកើនឡើងស្ទើរតែទាំងអស់ ក្នុងនោះរួមមាន ÷ ផ្នែកផលិតភេសជ្ជៈកើនឡើងប្រមាណ ២៤,៦៤% សេវាហិរញ្ញវត្ថុកើនឡើងប្រមាណ ២០,៩១% ទូរគមនាគមន៍កើនឡើងប្រមាណ ៩,៤៤% ផ្នែកស្ថាបត្យកម្មនិងសំណង់កើនឡើងប្រមាណ ៦៧,៣៦% ផលិតគ្រឿងប្រើប្រាស់កើនឡើងប្រមាណ ៣២,៧៥% ផលិតសម្លៀកបំពាក់កើនឡើងប្រមាណ ៤៥,០៨% នីហរ័ណអាហរ័ណកើនឡើងប្រមាណ ១២,៤៣% ផ្នែកសណ្ឋាគារនិងផ្ទះសំណាក់កើនឡើងប្រមាណ ៤៥,៦៩% ផលិតថ្នាំជក់កើនឡើងប្រមាណ ១០,១១% អាជីវកម្មអចលនទ្រព្យកើនឡើងប្រមាណ ១០១,៣២% លក់ភេសជ្ជៈកើនឡើងប្រមាណ ៣០,៥២% លក់សម្ភារការិយាល័យកើនឡើងប្រមាណ ៤០,៦៣% ផលិតម្ហូបអាហារកើនឡើងប្រមាណ ៧៨,២៤% ផ្នែកលក់គ្រឿងយន្តកើនឡើងប្រមាណ ៦៨,៣៩% លក់ផលិតផលឱសថកើនឡើងប្រមាណ ២០៨,៧០% និងលក់គ្រឿងសំណង់កើនឡើងប្រមាណ ២.៦៨៤.២១%។

ក្នុងការពិភាក្សាអង្គប្រជុំបានផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចជា I-របាយការណ៍លទ្ធផលប្រមូលចំណូលពន្ធប្រចាំខែរបស់នាយកដ្ឋាននិងសាខាពន្ធដារខេត្ត-ខណ្ឌ II- ការកែទម្រង់បែបបទ និងនីតិវិធីនៃការចុះបញ្ជីសហគ្រាសតាមប្រព័ន្ធអេឡិចត្រូនិក (E-Registration) III-របាយការណ៍វឌ្ឍនភាព នៃការប្រមូលពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ២០១៤ IV-របាយការណ៍វឌ្ឍនភាពនៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយាន

ជិនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៤ V-វឌ្ឍនភាពនៃការចាត់អាជីវកម្មដ្ឋានជាប់ពន្ធតាមរបបម៉ៅការទៅរបបស្វ័យប្រកាស VI-វឌ្ឍនភាពការងារផ្អែកតាមផែនការសកម្មភាពដោះស្រាយបញ្ហាជាក់ស្តែងរបស់អគ្គនាយកដ្ឋានពន្ធដារ VII -បញ្ហាផ្សេងៗ។

ដើម្បីប្រមូលចំណូលបានគ្រប់តាមផែនការច្បាប់ និងដើម្បីធានាបាននូវភាពជឿទុកចិត្តផ្នែកថវិកាសម្រាប់បម្រើឲ្យកិច្ចការគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ អគ្គនាយកដ្ឋានបានដាក់ចេញនូវទិសដៅ និងវិធានការមួយចំនួនដូចខាងក្រោម ៖

- បន្តរៀបចំសេចក្តីព្រាងច្បាប់ បទប្បញ្ញត្តិ និងលិខិតគតិយុត្តនានាដែលនៅខ្វះចន្លោះ ដូចជា សេចក្តីព្រាងប្រកាសស្តីពីពន្ធលើប្រតិបត្តិការប្រេងកាតនិងបទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការ ធនធានរ៉ែ និងធនធានធម្មជាតិ ជាដើម
- ត្រៀមរៀបចំកិច្ចចរចាជាមួយប្រទេសដៃគូ
- ពង្រឹងយន្តការនៃការត្រួតពិនិត្យ វាយតម្លៃ តាមដានស្ថានភាពកាតព្វកិច្ចសារពើពន្ធរបស់សហគ្រាសដែលទទួលបានវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែមរួចហើយ ប៉ុន្តែមិនបានមកដាក់លិខិប្រកាសបង់ពន្ធ ឬប្រកាសគ្មានសកម្មភាព ឬប្រកាសសូន្យ
- បន្តពង្រឹង និងជំរុញការចាត់បញ្ចូលទៅរបបស្វ័យប្រកាសនូវអាជីវកម្មដ្ឋានដែលបង់ពន្ធតាមរបបម៉ៅការ
- ជំរុញបញ្ចប់គម្រោងដាក់ឲ្យដំណើរការ នៃការគ្រប់គ្រងប្រមូលពន្ធតាមប្រព័ន្ធអេឡិចត្រូនិក (E-Tax) ការចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិក អនឡាញ (E-Registration) ក្នុងគោលដៅ ពង្រឹងនិងបង្កើនប្រសិទ្ធភាពនៃការចុះបញ្ជីពន្ធ ការផ្តល់សេវាជូនអ្នកជាប់ពន្ធ និងការគ្រប់ គ្រងការដាក់លិខិតប្រកាសបង់ពន្ធ ការធ្វើសវនកម្ម ព្រមទាំងការប្រមូលបំណុលពន្ធ ឲ្យកាន់តែមានតម្លាភាព និងប្រសិទ្ធភាពខ្ពស់។
- ពង្រឹងយន្តការនៃការតឹងទារបំណុលពន្ធ ព្រមទាំងរៀបចំសេចក្តីព្រាងសេចក្តីណែនាំស្តីពីការគ្រប់គ្រងនិងការប្រមូលបំណុលពន្ធ
- ជំរុញបញ្ចប់ការពិនិត្យសេចក្តីព្រាងប្រកាសស្តីពីនិយមន័យនៃពាក្យសេវាគ្រប់គ្រង សេវាបច្ចេកទេស និងសេវាពិគ្រោះយោបល់
- បន្តអនុវត្តការងារតាមការកំណត់ក្នុងកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ជាពិសេស ទាក់ទងនឹងសកម្មភាពកែលម្អគោលនយោបាយសារពើពន្ធ និងការពង្រឹងរដ្ឋបាលសារពើពន្ធ
- បន្តការផ្សព្វផ្សាយដល់ការបង់ពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ២០១៤ និងពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៤ ដើម្បីឲ្យម្ចាស់អចលនទ្រព្យនិងម្ចាស់យានជំនិះគ្រប់ប្រភេទ មកបង់ពន្ធបានទាន់ពេលវេលាតាមការកំណត់ដោយច្បាប់។ ទន្ទឹមនោះ ពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ២០១៤នេះ នឹងត្រូវបញ្ចប់នូវការទទួលប្រកាសបង់ពន្ធនៅថ្ងៃទី ៣០ ខែកញ្ញា ខាងមុខនេះ។
- បន្តលើកកម្ពស់ និងបញ្ជ្រាបវប្បធម៌ពន្ធដារឲ្យបានជ្រួតជ្រាបដល់គ្រប់មជ្ឈដ្ឋានប្រជាពលរដ្ឋ តាមរយៈការអប់រំ ផ្សព្វផ្សាយឲ្យបានទូលំទូលាយថែមទៀត រៀបចំផលិតកម្មវិធីផ្សព្វផ្សាយតាមបណ្តាញទូរទស្សន៍ បង្កលក្ខណៈ ងាយស្រួលដល់អ្នកជាប់ពន្ធ ពន្យល់ណែនាំអ្នកជាប់ពន្ធឲ្យយល់ដឹងកាន់តែច្បាស់និងចូលរួមបំពេញកាតព្វកិច្ចពន្ធ ដោយរីករាយ និងដោយស្ម័គ្រចិត្ត មិនបង្កការលំបាក មិនធ្វើឲ្យអ្នកជាប់ពន្ធមានអវិភាពក្នុងចិត្តពេលមកបង់ពន្ធ ព្រមទាំងកាត់បន្ថយការរអ៊ូរទាំរបស់អ្នកជាប់ពន្ធឲ្យបានជាអតិបរមា
- អប់រំណែនាំ ពង្រឹងសមត្ថភាព និងពង្រឹងការអនុវត្តច្បាប់ក្នុងចំណោមមន្ត្រីពន្ធដារគ្រប់លំដាប់ថ្នាក់តាមរយៈការចាត់វិធានការរដ្ឋបាល និងវិធានការច្បាប់ជាបន្តបន្ទាប់ ចំពោះមន្ត្រីពន្ធដារដែលមិនគោរព

ច្បាប់ មិនគោរពកាតព្វកិច្ចការងារ ពោលគឺបំពេញភារកិច្ចការងារដោយខ្វះអប្បមាទ (vigilance) សំដៅធានាបាននូវប្រសិទ្ធភាព តម្លាភាព ទំនួលខុសត្រូវខ្ពស់ ដោយឈរលើមនសិការ ស្មារតីតម្កល់ផលប្រយោជន៍ជាតិ ជាចម្បង

- បន្តពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ក្នុងចំណោមធុរជន សំដៅបង្កបរិកាសធុរកិច្ច និងការប្រកួតប្រជែងដោយស្មើភាពគ្នា ព្រមទាំងធ្វើឲ្យមានសង្គតិភាពក្នុងការអនុវត្តច្បាប់។

ជាកិច្ចបញ្ចប់ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានវាយតម្លៃខ្ពស់ដល់គ្រប់អង្គភាពពន្ធដារ ដែលបានប្រឹងប្រែងខិតខំប្រមូលចំណូលមានការកើនឡើងគួរជាទីពេញចិត្ត និងផ្តល់អនុសាសន៍ណែនាំបន្ថែមដល់អស់លោកជាប្រធានអង្គភាពពន្ធដារគ្រប់លំដាប់ថ្នាក់និងមន្ត្រីពន្ធដារទាំងអស់ឲ្យខិតខំពង្រឹងការអនុវត្តច្បាប់ វិន័យការងារ និងក្រមសីលធម៌ វិជ្ជាជីវៈមន្ត្រីពន្ធដារឲ្យបានល្អប្រសើរ តាមរយៈការផ្តល់សេវាអ្នកជាប់ពន្ធប្រកបដោយប្រសិទ្ធភាព និងភាពទន់ភ្លន់ តែម៉ឺងម៉ាត់ ដោយគោរពច្បាប់និងបទប្បញ្ញត្តិជាគោល ធ្វើយ៉ាងណាឲ្យអ្នកជាប់ពន្ធរីករាយក្នុងកិច្ចសហការបង់ពន្ធជូនរដ្ឋ និងកិច្ចពង្រឹងរដ្ឋបាលសារពើពន្ធដើម្បីការប្រមូលពន្ធឲ្យកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ថែមទៀត ដើម្បីឈានទៅសម្រេចបានតាមផែនការក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។

**អគ្គនាយកដ្ឋានពន្ធដារ**